# សេចក្តីថ្លែងការណ៍
# នៃក្រុមសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល សមាគម នៃ សង្គមស៊ីវិលកម្ពុជា

ថ្ងៃទី៩ ខែមិនា ឆ្នាំ២០១០

ក្រុមសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល-សមាគមនៃសង្គមស៊ីវិលមានការរីករាយណាស់ ដែលបានទទួលដំណឹងថារដ្ឋសភាជាតិនឹងធ្វើការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយនៅថ្ងៃទី១០ ខែមិនា ស្អែកនេះ តែយើងទាំងអស់គ្នាក៏មានការសោកស្តាយខ្លាំងណាស់ដែរ ដែលយើងទាំងអស់គ្នាបានទទួលនូវសំណៅនៃសេចក្តីព្រាងច្បាប់នេះក្នុងរយៈពេលខ្លីពេក ដែលមិនមានពេលគ្រប់គ្រាន់នឹងអាចធ្វើការវិភាគ និងធ្វើអនុសាសន៍ជូនទៅរដ្ឋសភាជាតិនូវមតិល្អៗបាន។ យើងទាំងអស់គ្នាក៏ទទួលស្គាល់ថាមតិខ្លះរបស់ អង្គការមិនមែនរដ្ឋាភិបាល-សមាគមនៃសង្គមស៊ីវិល ផ្តល់ជូនជាយុទ្ធសាស្ត្រកន្លងមកនោះ ត្រូវបានរាជរដ្ឋាភិបាលដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់នេះ និងក្នុងក្រមព្រហ្មទណ្ឌ (បទល្មើសពាក់ព័ន្ធនឹងអំពើពុករលួយ) រួចពិតមែនហើយ ប៉ុន្តែនៅមានគោលការណ៍ និង ទស្សនៈ មួយចំនួន ដែលសំខាន់ៗជាច្រើនទៀតនៅមិនទាន់បានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់នេះនៅឡើយនោះទេ។ ប្រសិនបើគោលការណ៍ និងទស្សនៈទាំងនោះមិនបានដាក់បញ្ចូលនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីទេនោះ ស្ថាប័នប្រឆាំងអំពើពុករលួយ ប្រាកដជាមិនអាចធ្វើសកម្មភាពរបស់ខ្លួនដោយមានប្រសិទ្ធិភាព និង ពេញលេញបានឡើយ ហេតុដូច្នេះដើម្បីធ្វើឱ្យក្រុមប្រឹក្សាជាតិ និង អាជ្ញាធរជាតិប្រឆាំងអំពើពុករលួយ អាចនឹងដំណើរការការងាររបស់ខ្លួនក្នុងការអនុវត្តក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយនេះដោយមានប្រសិទ្ធិភាពនោះ យើងខ្ញុំតំណាងឱ្យសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាល-សមាគមនៃសង្គមស៊ីវិលមានអនុសាសន៍ មួយចំនួនដូចខាងក្រោមៈ

១ **សូមធ្វើការពន្យារការអនុម័តសេចក្តីព្រាងច្បាប់**យ៉ាងហោចបានមួយខែទៀត និង សូមឱ្យរដ្ឋសភាបើកឱ្យមានការផ្តល់មតិសាធារណៈ ។

២ **ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**ត្រូវតែជាស្ថាប័នឯករាជ្យៈ ដើម្បីឱ្យក្រុមប្រឹក្សានេះឯករាជ្យទៅបានលុះត្រាតែៈ

- **អាណត្តិៈ** សមាជិកក្រុមប្រឹក្សាគួរតែមានអាណត្តិឱ្យបានយូរជាងនេះ (យ៉ាងតិច ៨ឆ្នាំ) សូមធ្វើវិសោធនកម្ម មាត្រា.៧ ។
- **ថវិកាៈ** សូមឱ្យមានថវិកាដោយឡែកនៅក្នុងកញ្ចប់ថវិកាជាតិ (សូមធ្វើវិសោធនកម្ម មាត្រា.១៦)។
- **សមាជិកៈ** គួរតែជាបុគ្គលឯករាជ្យ ដែលមិនមែនជាសកម្មជនគណបក្សនយោបាយ និង មិនមែន ជាមន្ត្រីរាជការ ដែលធ្វើការនៅក្នុងអំណាចនីតិប្រតិបត្តិ ឬ នីតិបញ្ញត្តិ ។

៣ **ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**មិនត្រូវជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយនោះទេ (សូមធ្វើវិសោធកម្ម ម.៦) ។

៤ **ការប្រកាសទ្រព្យសម្បត្តិ** គួរតែបានប្រកាសជាសាធារណៈ ។

៥ **ការការពារការសាក្សី និង អ្នកប្តឹងៈ** ច្បាប់នេះគួរតែលើកទឹកចិត្តឱ្យមានអ្នកចូលរួមផ្តល់ពត៌មានពីអំពើពុករលួយ តែផ្ទុយទៅវិញ ដូចជាមាត្រា ៤១ ជាដើម បែរជាធ្វើឱ្យអ្នកប្តឹងលែងហ៊ានប្តឹង អ្នកផ្តល់ពត៌មានមកអាជ្ញាធរក៏លែង ហ៊ានផ្តល់ពត៌មានដែរ ។ ដូចនេះ មាត្រាបែបនេះគួរតែចែងឱ្យបានច្បាស់ ឬ ដកទុកទម្រាំតុលាការរឹងមាំ ឯករាជ្យជាមុនសិន ។

យើងខ្ញុំតំណាងអង្គការមិនមែនរដ្ឋាភិបាល-សមាគមនៃសង្គមស៊ីវិល សង្ឃឹមថារាជរដ្ឋាភិបាល និង រដ្ឋសភាជាតិ នឹងធ្វើការពិចារណាទៅលើអនុសាសន៍របស់យើងខ្ញុំ និងសង្ឃឹមថាសង្គមកម្ពុជានឹងអាចកាត់បន្ថយអំពើពុករលួយប្រកបដោយតម្លាភាព គណនេយ្យភាព និងបើកឱ្យប្រជាជន គ្រប់រូបមានឱកាសចូលរួមក្នុងកិច្ចកសាងប្រទេសជាតិកម្ពុជា ។


*សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងជាមួយៈ*

| | | | |
|---|---|---|---|
| ១ | លោក **សុក សំអឿន** | នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងជាប្រធានសម្ព័ន្ធដើម្បីសុច្ចរិតភាព និងគណនេយ្យភាពសង្គម (CISA) | លេខទូរស័ព្ទៈ ០១២ ៩០១ ១៩៩ |
| ២ | លោក **ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC) | លេខទូរស័ព្ទៈ ០១៦ ៨៨០ ៥០៩ |
| ៣ | លោកស្រី **ពុង ឈីវកេក** | ប្រធានអង្គការលីកាដូ និងជាប្រធាន NGO CEDAW | លេខទូរស័ព្ទៈ ០១២ ៨០២ ៥០៦ |
| ៤ | លោក **ហង្ស ឆាយា** | នាយកប្រតិបត្តិអង្គការ KID | លេខទូរស័ព្ទៈ ០១២ ៨៦៥ ៩១០ |
| ៥ | លោក **ឈិត សំអាត** | នាយកប្រតិបត្តិ NGO Forum | លេខទូរស័ព្ទៈ ០១២ ៩២៨ ៥៨៥ |
| ៦ | លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ COMFREL | លេខទូរស័ព្ទៈ ០១២ ៩៤២ ០១៧ |
| ៧ | លោកស្រី **ធីតា ឃីះ** | នាយកប្រតិបត្តិអង្គការ SILAKA | លេខទូរស័ព្ទៈ ០១២ ៨៣៨ ៤៦៤ |